# ពាក្យពេចន៍ខ្លះគួរពិចារណា

## សម្រង់ចាកគម្ពីរស្រីហិតោបទេស

### បកប្រែចេញពីភាសាសំស្ក្រឹត ដោយព្រះភិក្ខុប៉ាង ខាត់

(បោះពុម្ពឆ្នាំ១៩៥៤)

☸ ការបរិភោគអាហារ១ ការដេក១ ភាពភ័យខ្លាច១ និងការសេពមេថុន១ រឿងទាំងបួនប្រការនេះ មនុស្សនិងសត្វមានស្មើគ្នា មានតែព្រះធម៌ប៉ុណ្ណោះ ទើបអាចធ្វើអោយមនុស្សវិសេសខុសប្លែកពីសត្វ។ នរណាប្រាសចាកធម៌ អ្នកនោះទុកស្មើសត្វ។

☸ សេចក្តីក្រោធកើតមកពីលោភៈ កាមរាគកើតមកពីលោភៈ មោហៈនិង សេចក្តីវិនាសក៏កើតមកពីលោភៈដែរ ព្រោះហេតុនេះ លោភៈជាប្រភពនៃ សេចក្តីអាក្រក់គ្រប់ប្រការ។

☸ បណ្តាទ្រព្យទាំងពួង វិជ្ជាលោកពោលថាជាទ្រព្យដ៏ប្រសើរឧត្តម ព្រោះវិជ្ជា ចោរលួចមិនបានផង កាត់ថ្លៃមិនបានផង មិនចេះរិចរិលអស់ទៅសព្វៗផង។

☸ បុគ្គលទាំងឡាយណាដែលប្រាថ្នាសេចក្ដីសុខចំរើន គួរគប្បីលះបង់ទោសទាំង៦ប្រការនេះ គឺដេកទ្រមក់១ ខ្ជិលច្រអូស១ ភ័យខ្លាចច្រើន១ ក្រោធខឹងច្រើន១ ទន់ជ្រាយមូមុខ១ និងចំអៀកយឺតយ៉ាវទៅណាមិនទាន់គេ១ ។

☸ រថមិនអាចបរទៅមុខបានដោយកង់តែមួយ យ៉ាងណាព្រេងវាសនាបើប្រាសចាកការព្យាយាមនៃមនុស្សហើយ ក៏មិនបានសំរេចយ៉ាងនោះដែរ ។ បើបុគ្គលមិនព្យាយាមចំរាញ់ ល្ងមិនចេញប្រេងទេ ។

☸ ការទាំងឡាយរមែងសំរេចដោយសេចក្ដីព្យាយាមប្រឹងប្រែង ដូចម្រឹគទាំងឡាយ រមែងមិនបោលចូលមាត់សីហៈដែលដេកលក់ឡើយ ។

☸ របស់សូម្បីតូចឆ្មារយ៉ាងណា កាលបើគេយកមកវេញចងរួមរួមគ្នាហើយ ក៏អាចកើតជាវត្ថុអាចញ៉ាំងការងារអោយសំរេចជាប្រយោជន៍បាន ដូចគេប្រមូលស្មៅវេញជាទន្លីងយកទៅធ្លីង ( ចងរូបជើងទាំងពីរ ) ដំរីចុះប្រេងអោយជាប់បោលទៅណាមិនរួច ។

☸ កិច្ចការអ្វីមួយដែលប្រកបដោយអំពើឥតប្រយោជន៍ ក៏រមែងមិនបានផលសមតាមប្រាថ្នាទេ ដូចជាប្រើវេលាព្យាយាមបង្រៀនសត្វកុកអោយចេះនិយាយដូចសត្វសេក សូម្បីច្រើនរយដង នឹងមិនបានផលដូចបំណងឡើយ ។

☸ ដង្កូវឡើងទំនៅលើក្បាលសាធុជនទាំងឡាយបាន ព្រោះនៅលាយឡំនឹងផ្កា ដុំថ្មដែលអ្នកធំលើកដំកើងហើយ ក៏ក្លាយជាមានទេវភាពពូកែសក្តិសិទ្ធ ។

☸ អ្នកប្រាជ្ញ កាលបើស្វែងរកវិជ្ជានិងទ្រព្យ គប្បីគិតថាខ្លួនដូចជាមិនចាស់មិនស្លាប់ កាលបើស្វែងរកធម៌ គប្បីគិតថាខ្លួនត្រូវម្រឹត្យុចាប់ក្របួចសក់បោកសំលាប់ឥឡូវនេះហើយ ។

☸ អ្នកប្រាជ្ញតែងប្រើកាលវេលាអោយប្រព្រឹត្តទៅដោយការស្វែងរកធម៌និង វិជ្ជា ឬការកំសាន្តកាព្យសាស្ត្រ មនុស្សល្ងង់តែងប្រើកាលវេលាអោយប្រព្រឹត្តទៅដោយការប្រព្រឹត្តសេចក្តីវិនាស ដោយការដេក លេងល្បែងពាលា និង ឈ្លោះទាស់ទែងគ្នា ។

☸ មនុស្សល្ងង់ប្រដាប់កាយដោយគ្រឿងអម្ពរ តែងមានរាសីរុងរឿងក្នុងទីប្រជុំជន ។ ដរាបណាមនុស្សល្ងង់នោះមិនទាន់ហាមាត់ចេញនិយាយ ក៏នៅតែមានរាសីរុងរឿងដរាបនោះ ។

☸ កូនមានគុណគាប់តែម្នាក់ប្រសើរជាងកូនល្ងង់រាប់រយ ប្រៀបដូចច័ន្ទតែមួយដួងអាចកំចាត់ភាពងងឹតអន្ធកាបាន កងតារាទាំងឡាយកំចាត់បង់ភាពងងឹតមិនបានឡើយ ។

❁ អ្នកមានគុណគាប់តែងដឹងល្អនិងអាក្រក់។ អ្នកមានគុណគាប់នោះ បើទៅសេពគប់នឹងមនុស្សអាក្រក់ ក៏ត្រលប់ទៅជាអាក្រក់វិញ ដូចទឹកស្ទឹងមានរសជាតិល្អ លុះហូរចូលដល់សមុទ្រហើយក៏ក្លាយជាមានរសប្រៃ ផឹកមិនបាន។

❁ កញ្ចក់នៅជាមួយនឹងមាស អាចចោលស្រមោលមាស យ៉ាងណាមនុស្សល្ងង់នៅរួមជាមួយនឹងលោកសប្បុរស ក៏អាចត្រលប់ក្លាយជាសប្បុរសឆ្លៀវឆ្លាតយ៉ាងនោះបានដែរ។

❁ អ្នកប្រាជ្ញមានចិត្តល្អ សូម្បីខ្សត់ទ្រព្យហើយឥតកំលាំង ក៏គង់នៅអាចជួយកែខៃអោយសំរេចផលប្រយោជន៏បាន។

❁ ជីវិតរបស់ខ្លួនជាទីស្រលាញ់ពេញចិត្តយ៉ាងណា ជីវិតរបស់ជនដទៃក៏យ៉ាងនោះ។

❁ កំណាញ់និងការអោយទាន សេចក្ដីសុខនឹងសេចក្ដីទុក្ខ ស្រលាញ់និងស្អប់ បុគ្គលអាចយកប្រមាណសេចក្ដីបាន ដោយយកខ្លួនរបស់លោកជាគ្រឿងឧបមា។

❁ បុគ្គលកុំគប្បីចងមិត្តសំលាញ់ ឬចងស្ពានមេត្រីនឹងមនុស្សទុជិន ដូចជាធ្យូងបើនៅក្ដៅវារលាកដៃ បើរលត់ហើយវាប្រលាក់ដៃ។

☸ នរជនណាបានឃើញភរិយាអ្នកដទៃ ទុកស្មើនឹងមាតារបស់ខ្លួន ឃើញទ្រព្យអ្នកដទៃទុកស្មើដុំថ្ម ឃើញសព្វសត្វទាំងឡាយទុកស្មើដោយរូបខ្លួនឯង នរជននោះ លោកហៅថា "បណ្ឌិត" ។

☸ បុគ្គលមិនគួរធ្វើសេចក្តីស្និទ្ធស្នាលទុកចិត្តទឹកទន្លេ បុគ្គលមានសាស្ត្រាវុធក្នុងដៃ សត្វមានចង្កូមក្រចកមុត សត្វមានស្នែង និងស្ត្រីក្នុងរាជត្រកូលទាំងឡាយ ។

☸ បុគ្គលមានឥច្ឆាឈ្នានីស បុគ្គលពោលពាក្យនិន្ទារិះគន់ បុគ្គលមិនសន្តោសបុគ្គលក្រោធច្រើន បុគ្គលមានសេចក្តីរង្កៀសជានិច្ច និងបុគ្គលពឹងផ្អែកស៊ីតែដោយសារបុគ្គលដទៃ បុគ្គលទាំង៦បែបនេះត្រូវទទួលចំណែកនៃសេចក្តីទុក្ខ ។

☸ បុគ្គលណាមួយអាចជួយអ្នកមានគ្រោះអោយរួចពីក្តីអន្តរាយដែលមកដល់អ្នកនោះ លោកទុកជាផៅពង្ស ឯអ្នកបណ្ឌិតដែលបានតែមាត់ បានតែពោលទំលាក់កំហុសទៅលើគេ នឹងរាប់ថាជាផៅពង្សពុំបានឡើយ ។

☸ កិរិយាចូលចិត្តទំលាយអាថិកំបាំង លោភស្នូម ចរិតរឹងរូស ចរិតរបិលរប៉ូចភាពមានសេចក្តីក្រោធច្រើន ភាពជាបុគ្គលគ្មានសច្ចៈ ការស្រវឹងឈ្លក់នឹងល្បែងទាំងអស់នេះជាគ្រឿងប្រទូស្តនៃមិត្ត ។

☸ ចំពោះមនុស្សចិត្តអាក្រក់ ចិត្តគិតផ្សេង សំដីនិយាយផ្សេង កិរិយាប្រព្រឹត្តធ្វើផ្សេងទៅទៀត ។ មនុស្សបែបនោះ លោកថាកុំយកខ្លួនបៀត ។

☸ ទីស្ថានណាដែលមិនមានអ្នកប្រាជ្ញបណ្ឌិត ទីស្ថាននោះ សូម្បីតែមានអ្នកចេះដឹងបន្តិចបន្តួច ក៏គួរលើកតំកើងសរសើរ ដូចជាប្រទេសណាមួយដែលឥតមានព្រឹក្សាជាតិ បើមានតែដើមល្ហុង ក៏លោកសន្មតថាជាដើមឈើបានដែរ ។

☸ អ្នកនេះជាពួកយើង អ្នកនោះជាពួកគេ នេះជាសំដីអ្នកមានគំនិតស្រាលទេ អ្នកដែលមានការសិក្សាច្រើន មានចិត្តគំនិតល្អ តែងនិយាយថា អ្នកនៅលើផែនពសុធាសុទ្ធតែជាផៅពង្សនឹងគ្នាទាំងអស់ ។

☸ នឹងថានរណាជាមិត្តនរណាក៏ពុំទាន់បាន នឹងថានរណាជាសត្រូវនឹងនរណាក៏ពុំទាន់បាន លុះដោយអំពើគេប្រព្រឹត្ត ទើបស្គាល់ថា "អ្នកនេះជាមិត្ត អ្នកនោះជាសត្រូវ" ។

☸ គេដឹងចិត្តមិត្តក្នុងគ្រាក្រ ដឹងចិត្តទាហានក្លៀវក្លាក្នុងសង្គ្រាម ដឹងចិត្តមនុស្សស្មោះត្រង់ក្នុងការសងបំណុលគេ ដឹងចិត្តភរិយាក្នុងពេលខ្សត់ទ្រព្យ និងដឹងចិត្តផៅពង្សក្នុងគ្រាវិនាសអន្តរាយ ។

☸ របស់ណាមិនអាច របស់នោះនៅតែមិនអាចពិតប្រាកដ ។ របស់ណាអាច របស់នោះនៅតែអាចពិតប្រាកដ ដូចជាបររទេះលើទឹកក៏មិនបាន ឯអុំទូកលើគោកក៏មិនបានដូច្នោះដែរ ។

☸ ការគ្រាន់តែប្រដៅនរជនទាំងឡាយដទៃ អោយគេជាបណ្ឌិត នរណាក៏ធ្វើបាន តែការទូន្មានខ្លួនឯងអោយប្រព្រឹត្តិទៅតាមគន្លងធម៌មិនជាការក្រ ធ្វើបានតែចំពោះបុគ្គលមានមហាត្ម័ន ។

☸ រស់នៅក្នុងខ្ទមប្រសើរជាងរស់ក្នុងផ្ទះឥស្សរជនកាចកំរោល យកស្ត្រីផ្កាមាសជាភរិយាប្រសើរជាងយកស្ត្រីមានត្រកូលដែលប្រព្រឹត្តកន្លងប្រពៃណី រស់នៅក្នុងព្រៃប្រសើរជាងរស់ក្នុងបុរីដែលមានស្តេចមានចិត្តអយុត្តិធម៌ ។

☸ ពន្លឺត្រជាក់នៃព្រះច័ន្ទ មិនជាទីពេញចិត្តនៃមនុស្សរងា ពន្លឺក្តៅនៃព្រះអាទិត្យ មិនជាទីពេញចិត្តនៃមនុស្សក្តៅក្រហល់ក្រហាយ ។

☸ សេចក្តីប្រាថ្នាចង់បានទ្រព្យសម្បត្តិ សេចក្តីប្រាថ្នាចង់មានអាយុយឺនយូរ ជាធម៌តែងមាននៅជាប់ក្នុងចិត្តនៃសព្វសត្វទាំងឡាយ ។

☸ នារីបីដូចជាឆ្នាំងខ្លាញ់ បុរសបីដូចភ្លើង ហេតុនោះបានជាអ្នកប្រាជ្ញលោក មិនអោយតំកល់ឆ្នាំងខ្លាញ់នៅជិតភ្លើង ។

☸ ធម្មជាតិជាស្ត្រី នឹងថាអៀនខ្មាសក៏មិនមែន នឹងថាមានការទូន្មានល្អក៏មិនមែន នឹងថាមានចិត្តស្មោះត្រង់ចំពោះប្តីក៏មិនមែន នឹងថាមានសេចក្តីភ័យខ្លាចក៏មិនមែនដែរ សេចក្តីពិត គឺមិនមានបុរសចង់ នោះជាហេតុនៃសេចក្តីបរិសុទ្ធរបស់ស្ត្រី ។

☸ អ្នកប្រាជ្ញនិងផ្កាមានសភាពដូចគ្នា ស្ថិតនៅក្នុងគតិតែពីរយ៉ាង : ១. ទំលើក្បាលនៃនរជនទាំងពួង ២. ស្រពោនស្វិតក្រៀមនៅលើដើម ។

☸ សេចក្តីក្រីក្រនាំអោយកើតក្តីអៀនខ្មាស ក្តីអៀនខ្មាសនាំអោយបាត់ក្តីក្លាហាន បាត់ក្តីក្លាហាននាំអោយបុគ្គលដទៃមើលងាយ ការត្រូវគេមើលងាយនាំអោយកើតក្តីស្អប់ខ្ពើម ក្តីស្អប់ខ្ពើមនាំអោយកើតក្តីទុក្ខសោក ក្តីទុក្ខសោកនាំអោយអាប់ប្រាជ្ញា ... ។

☸ គប្បីលះបង់បុគ្គលម្នាក់ដើម្បីស្រង់ត្រកូល គប្បីលះបង់ត្រកូលដើម្បីរក្សាភូមិ គប្បីលះបង់ភូមិដើម្បីរក្សាប្រទេស គប្បីលះបង់ប្រទេសដើម្បីស្រោចស្រង់ខ្លួន ។

☸ នរជនជាបណ្ឌិតមានប្រាជ្ញាល្អ តែងមិនរវល់ចង់បានទ្រព្យសម្បត្តិដែលមិនត្រូវបាន មិនកើតទុក្ខសោកសៅក្តៅក្រហាយស្តាយទ្រព្យដែលវិនាសបាត់ទៅ មិនវង្វេងជ្រប់ដល់បាត់ស្មារតីក្នុងពេលសេចក្តីក្រីក្រមកដល់ ។

☸ នរជនមានប្រាជ្ញា តែងនៅញាប់ញ័រដោយសេចក្តីលោភ សេចក្តីលោភនាំបង្កើតតណ្ហា  តណ្ហានាំបង្កើតអោយមានក្តីទុក្ខនៅលើលោកនេះ ។

☸ បុគ្គលជាអ្នកមានប្រាជ្ញា មិនរវល់យកចិត្តទុកដាក់ថា "ដូចម្តេចហៅថាប្រទេសខ្លួន ដូចម្តេចហៅថាបរទេស" ឡើយ  ចូលទៅក្នុងប្រទេសណា ក៏ខំប្រឹងប្រែងរកទ្រព្យដោយកំលាំងនៃខ្លួន ក្នុងប្រទេសនោះ ដូចសត្វសីហៈ ចូលទៅក្នុងព្រៃណា ក៏អាចចាប់សត្វដទៃសំលាប់ជាអាហារ ដើម្បីបំបាត់សេចក្តីស្រេកឃ្លានក្នុងព្រៃនោះ ។

☸ បុគ្គលមិនប្រឹងប្រែងរកទ្រព្យសម្បត្តិ ឈ្មោះថាប្រគល់ការសម្បូណ៌ទ្រព្យសម្បត្តិទៅលើដៃនរជនដែលមានសេចក្តីព្យាយាម ។

☸ ក្នុងលោកនេះ បើបុគ្គលគ្រប់គ្នាលះបង់តណ្ហាចោលអស់ តើបាននរណាធ្វើអ្នកក្រីក្រ?  បាននរណាធ្វើជាអ្នកធំមានព្រទ្យ?  តែថាបើបុគ្គលប្រគល់ខ្លួនអោយជាខ្ញុំកញ្ជះតណ្ហា នុ៎ះឈ្មោះថាបណ្តោយអោយទាសភាពមកទំលើអំបែងក្បាលប្រាកដតែម្តង!

☸ បុគ្គលគប្បីស្វែងរកទ្រព្យដែលមិនទាន់បាន គប្បីរក្សាទ្រព្យដែលរកបានហើយ កុំអោយវិនាសបាត់ទៅវិញអស់ គប្បីពូនទ្រព្យដែលរក្សាទុកនោះអោយចំរើនដោយប្រពៃ ។

☸ ទ្រព្យសម្បត្តិនៃមនុស្សកំណាញ់ ទុកដូចជាព្រទ្យនៃជនដទៃស្រេចទៅហើយ ព្រោះមិនបានរីករាយប្រើប្រាស់ខ្លួនឯង លុះទ្រព្យនោះដល់សេចក្តីសាបសូន្យ-ទៅហើយ នឹងបានសេចក្តីទុក្ខថែមទៀត។

☸ ការអោយទានទាំងមានវាចាពិរោះ ការចេះដឹងព្រមទាំងចិត្តធូន់ សេចក្តីក្លៀវក្លានិងភាពអំណត់ ការមានទ្រព្យព្រមដោយការបរិច្ចាគទាន បួនប្រការនេះជាមង្គលរបស់មនុស្សប្រសើរកម្រមាន។

☸ ទានជារបស់គួរគប្បីអោយ តែអោយដល់អ្នកមិនមានឧបការគុណ ក៏មិនសូវមានផលប្រយោជន៏ទេ។ ការអោយទានដែលអ្នកប្រាជ្ញពោលថាប្រកបដោយផលប្រយេជន៏នោះ គឺអោយទានត្រឹមត្រូវតាមកាលៈទេសៈ និងអោយដល់បុគ្គលដែលគួរអោយ។

☸ ទឹកស្រក់មួយតំណក់ៗជាលំដាប់ អាចពេញក្អមបាន នេះជាគ្រឿងឧបមានៃការរៀនសព្វវិជ្ជា ការប្រតិបត្តិធម៌ និងការសន្សំទ្រព្យសម្បត្តិ។

☸ ម្រឹគទាំងឡាយមិនបានធ្វើបុណ្យអភិសេកអោយសីហៈទេ សីហៈបានរាជ្យជាធំលើពួកសត្វម្រឹគដោយកំលាំងព្យាយាមនៃខ្លួនឯង។

☸ សេះ សាស្ត្រាវុធ សាស្ត្រវិជ្ជា ពិណ សុន្ទរកថា នរជននិងនារី វិសេសឬមិន
វិសេស ប្រើបានល្អឬមិនបានល្អ គឺអាស្រ័យលើវិធីសាស្ត្រនៃម្ចាស់អ្នកប្រើ ។

☸ បើនៅទ្រមឹងមិននិយាយច្រើន គេថាល្ងង់ បើនិយាយច្រើនគេថាឆ្កួត
បើចេះអត់ធ្មត់គេថាខ្លាច បើនៅជិតគេថាហ៊ានពេក បើនៅឆ្ងាយគេថា
ញញើតញញើម សូម្បីតែព្រះយោគីក៏ផ្គាប់ចិត្តម្ចាស់អោយពេញបរិបូណ៌
មិនបានដែរ ។

☸ បើបុគ្គលណាមានជីវិតរស់នៅ បានញ៉ាំងជនដទៃច្រើននាក់អោយមាន
ជីវិតរស់នៅបានផង សូមអោយបុគ្គលនោះមានជន្មាយុរស់នៅយឺនយូរ!

☸ មនុស្សខ្លះសុខចិត្តនៅជាខ្ញុំគេ ត្រឹមតែប្រាក់ប្រាំបុរាណៈ មនុស្សខ្លះទៀត
សុខចិត្តនៅជាខ្ញុំគេ លុះត្រាតែបានប្រាក់មួយសែនបុរាណៈ រីឯមនុស្សមួយពួក
ទៀត មិនសុខចិត្តធ្វើជាខ្ញុំគេ សូម្បីតែនៅចំពោះមុខប្រាក់ច្រើនជាងមួយសែន
បុរាណៈ ។

☸ ឆ្កែលុតក្រាបរាបទាបជិតជើងម្ចាស់ ហាមាត់បញ្ចេញចង្កូមបក់កន្ទុយរវិចៗ
នៅនឹងដី ចាំទទួលសំណល់អាហារដែលម្ចាស់បោះអោយ ដំរីមើលម្ចាស់ដោយ
ឫកមាំ លុះត្រាតែលួងលោមច្រើនដងទើបបរិភោគ ឯសីហៈដើរស្វែងរកចាប់
អាហារដោយខ្លួនឯង ។

☸ បុគ្គលណាដែលមិនផ្សាយសេចក្ដីសន្ដោសអាណិតអាសូរចំពោះកូនខ្លួន ចំពោះគ្រូ ចំពោះពួកខ្ញុំបំរើ ចំពោះជនក្រីក្រលំបាក និងចំពោះញាតិសន្ដាន ជីវិតនៃបុគ្គលនោះ តើបានជាប្រយោជន៍អ្វីលើលោកនេះ?

☸ កែវមណីត្រូវគេយកទៅដាក់ជាទ្រនាប់ជើង កញ្ចក់ត្រូវគេដាក់តំកល់លើសិរសា បើទុកជាដូច្នោះ របស់ណានៅតែជារបស់នោះដដែល គឺកែវមណីនៅតែជាកែវមណី កញ្ចក់នៅតែជាកញ្ចក់ ។

☸ លើកកញ្ចក់ទៅបន្ទុបលើកំពូលមកុដ សំរុតកែវមណីទៅជាប្រដាប់កងជើង នោះមិនមែនជាទោសរបស់កែវមណីឯណា គឺជាទោសនៃមនុស្សល្ងង់ មិនចេះប្រើ មិនស្គាល់តំលៃទេតើ!

☸ មិត្តណាជាទីស្រលាញ់ពេញចិត្ត បើទុកជាកុហកបោកប្រាសយើងខ្លះ សូម្បីធ្វើអោយយើងមិនពេញចិត្តពេលខ្លះ មិត្តនោះនៅតែជាទីស្រលាញ់ពេញចិត្តដដែល ដូចរាងកាយយើង ទោះបីមានរោគាព្យាធិ នរណាមួយមិនស្រលាញ់រាងកាយខ្លួន ឬប្រៀបដូចភ្លើង សូម្បីឆេះមន្ទីរមហាសាល នរណាមួយលែងនិយមរាប់អានភ្លើងទៀត?

☸ ធ្វើគុណដល់ជនអសប្បុរស ១០០ដង ឥតបានផល និយាយពាក្យសុភាសិតដល់មនុស្សល្ងង់ ១០០ដង ឥតអំពើ និយាយពាក្យពិរោះដល់មនុស្សគថ្លង់ ១០០ដង ឥតប្រយោជន៍ ប្រើឧបាយប្រាជ្ញា១០០ដង ចំពោះជនឥតការត្រិះរិះពិចារណា ក៏មិនបានការ ។

☸ មនុស្សឈឺអោយសេចក្ដីសុខចំរើនដល់ពេទ្យ មនុស្សមានវិបត្តិគ្រោះអោយសុខសេចក្ដីចំរើនដល់មន្ត្រី មនុស្សល្ងង់ជាការរស់នៅនៃអ្នកប្រាជ្ញ ។

☸ ភ័យនៅឆ្ងាយ មានក្ដីភ័យខ្លាច ភ័យមកដល់ជិត មានក្ដីក្លៀវក្លា នេះទើបជាគុណសម្បត្តិមហាបុរស ។

☸ ម្ចាស់ណាគិតតែខ្លួនម្នាក់ឯង ឥតពិចារណា កាចទ្រទង់មិនដឹងឧបការៈគេ ម្ចាស់នោះត្រូវអ្នកបំរើដែលប្រសើរលះបង់ចោល ។

☸ ក្រពើដ៏កាចពន់ពន្លឹក បើចេញផុតពីទឹកហើយ ក៏អន់អំណាច សីហៈសូម្បីកាចសាហាវ បើចេញផុតពីព្រៃហើយ ដូចគ្នានឹងសត្វចចក ។

☸ បុគ្គលដែលធ្លាក់ខ្លួនក្នុងគ្រោះកាច តែងតែបន្ទោសព្រេងវាសនា មនុស្សល្ងង់មិនព្រមទទួលកំហុសដែលខ្លួនបានធ្វើទេ ។

☸ អ្នកប្រាជ្ញ កាលបើគិតដល់សេចក្ដីចំរើនហើយ គួរគិតដល់សេចក្ដីវិនាសផង ។

☸ ការអោយផែនដី ការអោយមាសប្រាក់ ការអោយគោ ការអោយបាយទឹក លោកមិនទាន់ហៅថាមហាទានទេ អភ័យទានទើបលោកចាត់ថាជាមហាទាន ។

☸ ម្ចាស់ផែនដី គឺជាទីពឹងពាក់នៃពលរដ្ឋទាំងឡាយ ដូចជាទឹកភ្លៀងជាទីពឹងពាក់នៃសត្វទាំងឡាយ : បើភ្លៀងធ្លាក់រអាក់រអួល សត្វលោកនៅអាចញ៉ាំងជីវិតិន្ទ្រិយ៍អោយប្រព្រឹត្តទៅបាន តែបើព្រះរាជាមិនប្រកបដោយធមិ ពលរដ្ឋរស់នៅមិនបានទេ ។

☸ ក្នុងលោកនេះ នរជនប្រព្រឹត្តទៅតាមច្បាប់ ដោយច្រើនព្រោះខ្លាចទណ្ឌកម្មទេ នរជននៅក្នុងអំណាចគេ ហើយប្រព្រឹត្តល្អពិតមែននោះ រកបានដោយកម្រណាស់ ។

☸ នរជនណាដែលលះបង់របស់ទៀងទាត់ ទៅស្រវាយករបស់មិនទៀតទាត់ របស់ទៀងទាត់ក៏វិនាសបាត់សូន្យទៅ ឯរបស់ដែលមិនទៀងទាត់ក៏មិនបានមកដល់ដៃដែរ ។

☸ របស់ណាគាប់ចិត្តនរជនណា របស់នោះឈ្មោះថាល្អសំរាប់នរជននោះ ។

☸ ជីវិតនៃមនុស្សណា សូម្បីតាំងនៅតែមួយខណៈខ្លី តែមិនប្រាសចាកការចេះដឹង សេចក្តីព្យាយាមអង់អាច និងកេរ្តិ៍ឈ្មោះកិត្តិយស អ្នកប្រាជ្ញពោលថា ជីវិតនៃមនុស្សនោះ ពេញជាជីវិតដ៏ប្រសើរនៅនាលោកនេះ ។

☸ នរជនអប្បឥតប្រាជ្ញពិចារណា មានសេចក្តីប្រាថ្នាគ្រាន់តែបំពេញផ្ទៃខ្លួនប៉ុណ្ណោះ នរជននោះហៅថាមនុស្សតិរច្ឆាន ឯមនុស្សតិរច្ឆាននិងបសុសត្វមានសេចក្តីខុសប្លែកគ្នាដូចម្តេចខ្លះ?

☸ ពោលពាក្យអោយសមតាមកាលៈទេសៈ ធ្វើខ្លួនអោយគេស្រលាញ់ប្រាកដស្មើនឹងភាពអ្នកសប្បុរស ចេះក្រោធអោយសមតាមសក្តិខ្លួន  អ្នកណាចេះធ្វើដូច្នេះ  អ្នកនោះជាបណ្ឌិត ។

☸ មនុស្សរឹងរូសវិនាសយស មនុស្សមានចិត្តមិនត្រង់បាត់មិត្តភាព មនុស្សល្មោភមិនមានធមិ មនុស្សកំណាញ់វិនាសសេចក្តីសុខ ឯព្រះនរាធិបតីមានតែអាមាត្រឡៃបឡបស្រវឹងយសលាភ  វិនាសរាជ្យ ។